**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ.០០៥.....សហវ.......

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត សម្រាប់ឆ្នាំ២០២៣-២០២៥

### ១. សេចក្តីផ្តើម

មាត្រា៣៥នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១១ បានកំណត់ប្រតិទិននៃកិច្ចដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជា ៣ដំណាក់កាល÷ **ដំណាក់កាលទី ១** គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចាប់ពីខែមីនា ដល់ខែឧសភា, **ដំណាក់កាលទី ២** គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែមិថុនា ដល់ខែកញ្ញា និង**ដំណាក់កាលទី ៣** គឺការអនុម័តថវិកា ចាប់ពីខែតុលា ដល់ខែធ្នូ។ ក្នុងបរិការណ៍ដែលស្ថានភាពភូមិសាស្ត្រនយោបាយមានការប្រែប្រួលយ៉ាងឆាប់រហ័ស ដែលបង្កើតឱ្យមានភាពមិនប្រាកដប្រជាខ្ពស់ចំពោះចលនការងើបឡើងវិញផ្នែកសង្គម-សេដ្ឋកិច្ចតំបន់ និងសកលលោក ជាពិសេស ប៉ះពាល់ និងបញ្ហាយនៃការផ្ទុះឡើងនូវសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ដែលបាន និងកំពុងបន្តចំបង្អាក់ដល់ដំណើរការនៃនិម្នាបនកម្មសេដ្ឋកិច្ចតំបន់ និងសកល, រាជរដ្ឋាភិបាលបានសម្រេចរំកិលពេលវេលានៃការរៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ ២០២៣ ពីខែមីនា មកខែឧសភា ដូច្នេះ ពេលវេលានៃការរៀបចំសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តសម្រាប់ឆ្នាំ២០២៣-២០២៥ នឹងត្រូវរៀបចំដំណាលគ្នាជាមួយនឹងការរៀបចំសារាចរណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។

រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ ព្រមទាំងធ្វើការលើកគម្រោងថវិកាប្រចាំឆ្នាំ២០២៣មកដំណាលគ្នា ទៅតាមរចនាសម្ព័ន្ធកម្មវិធី និងគម្រោងចំណូល-ចំណាយថវិកា ទៅតាមទម្រង់នៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា។

សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត នឹងផ្តល់នូវគោលការណ៍ណែនាំថ្មីៗ និងជាមគ្គុទ្ទេសក៍បច្ចេកទេសគន្លឹះៗ សម្រាប់គ្រប់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រថវិកា ដែលជាផែនការថវិការយៈពេល០៣ឆ្នាំរំកិល។ ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍ដ៏សំខាន់សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងជាយន្តការក្នុងការជួយបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការប្រើប្រាស់ថវិកា តាមរយៈការជួយតម្រង់ និងជំរុញការវិភាជថវិកាឱ្យចំទិសដៅ, ការវិភាជថវិកាបម្រើឱ្យសកម្មភាពអាទិភាព និងការវិភាជថវិកាមានភាពជាក់ស្តែង ដើម្បីឆ្លុះបញ្ចាំងអំពីសមិទ្ធផលសម្រេចបានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងឆ្ពោះទៅការសម្រេចឱ្យបាននូវគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល។

ស្របតាមទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥, ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត នឹងក្លាយជាផែនការយុទ្ធសាស្ត្ររួម តាមរយៈការធ្វើសមាហរណកម្មផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការតម្រឹមជាមួយនឹងអាទិភាពតាមវិស័យនៃក្រសួង ស្ថាប័នថ្នាក់ជាតិ (មន្ទីរជំនាញរាជធានី ខេត្ត)។ ដំណើរការនេះ គឺធានាឱ្យមានការផ្សារភ្ជាប់គ្នាប្រកបដោយប្រសិទ្ធភាពរវាងផែនការ/កម្មវិធីនៃថវិកាថ្នាក់ក្រោមជាតិទៅនឹងអាទិភាពជាតិ ដើម្បីប្រើប្រាស់ធនធានដែលមានកម្រិតក្នុងការសម្រេចឱ្យបានសមិទ្ធផលជាអតិបរមា។ ផែនការអាទិភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ នឹងត្រូវដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ទៅតាមអាទិភាពនៅថ្នាក់មូលដ្ឋាន ដែលជាតម្រូវការ និងសំណូមពររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ តាមអភិក្រមពីក្រោមឡើងលើ។

ដើម្បីអាចរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត បានគ្រប់ជ្រុងជ្រោយ គឺតម្រូវឱ្យមានការកែលម្អដំណើរការប្រឹក្សាយោបល់ និងការសម្របសម្រួលរវាងក្រសួង ស្ថាប័ន (មន្ទីរជំនាញរាជធានី ខេត្ត), រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធ តាមរយៈយន្តការសម្របសម្រួល និងពិគ្រោះយោបល់របស់ *«គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស»* ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។ ជាមួយគ្នានេះ, ការបង្កើតឱ្យមានយន្តការគាំទ្រពីថ្នាក់ជាតិ ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺមានភាពចាំបាច់ណាស់។ តាមរយៈនេះ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំក្រុមការងារបច្ចេកទេសកម្រិតថ្នាក់ជាតិមួយ ហៅថា *«មន្ត្រីបច្ចេកទេសថវិកា»* ដើម្បីជួយដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការពិនិត្យឡើងវិញ និងកែលម្អរចនាសម្ព័ន្ធកម្មវិធី និងសូចនាករសមិទ្ធកម្ម ក្នុងគោលបំណងដើម្បីបង្កើនគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ក៏ដូចជាប្រសិទ្ធភាពក្នុងការរៀបចំថវិកាប្រចាំឆ្នាំ។ ដោយឡែក, អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក៏ត្រូវបង្កើត *«ក្រុមការងារថវិកា»* ដែលមានសមាសភាពអភិបាលនៃគណៈអភិបាលរាជធានី ខេត្តជាប្រធាន, ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តជាអនុប្រធាន និងមានការចូលរួមពីប្រធានរតនាគាររាជធានី ខេត្ត, នាយករដ្ឋបាល, នាយកទីចាត់ការហិរញ្ញវត្ថុ/ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ, នាយកទីចាត់ការផែនការ និងវិនិយោគ/ប្រធានការិយាល័យផែនការ និងវិនិយោគ និងប្រធានសាខាពន្ធដារខេត្ត ខណ្ឌ ជាសមាជិក។ ក្រុមការងារថវិកា ត្រូវធ្វើការគ្រោងធនធាន និងផែនការសកម្មភាព ទៅតាមរចនាសម្ព័ន្ធនៃកម្មវិធីនីមួយៗ ដោយត្រូវធ្វើយ៉ាងណាឱ្យការវិភាជថវិកាមានប្រសិទ្ធភាព និងចំទិសដៅ។ ក្រុមការងារនេះ ត្រូវរៀបចំយន្តការការងារឱ្យបានច្បាស់លាស់ និងតាមការចាំបាច់ ក្រុមការងារត្រូវធ្វើការសហការជាមួយមន្ទីរជំនាញរាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធ ដើម្បីធានាបាននូវនិរន្តរភាព និងប្រសិទ្ធភាពការងារ។ ទន្ទឹមនឹងនេះ, អភិបាលក្រុង ស្រុក ខណ្ឌនិងមេឃុំ ចៅសង្កាត់ ត្រូវចូលរួមសហការអនុវត្ត ដើម្បីឱ្យការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តទទួលបានជោគជ័យ។

ដើម្បីជួយដល់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ មានមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ ឱ្យកាន់តែមានភាពជាក់ស្តែងទៅតាមអាទិភាពគោលនយោបាយរបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌនីមួយៗ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមធ្វើការណែនាំដល់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌទាំងអស់នៅក្នុងផ្នែកបន្តបន្ទាប់ដូចខាងក្រោម។

## ២. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច, ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងទិសដៅថវិការហិរញ្ញវត្ថុ

### ២.១. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

ស្របគ្នានឹងការព្យាករសេដ្ឋកិច្ចសកលឡើងវិញ, សេដ្ឋកិច្ចកម្ពុជា ត្រូវបានរំពឹងថានឹងបន្តនិន្នាការកើនឡើងក្នុងអត្រា ៥,៥%ក្នុងឆ្នាំ២០២២ ដែលបន្តគាំទ្រដោយភាពល្អប្រសើរនៃតម្រូវការសកល បើទោះបីជារងការប៉ះទង្គិចពីការផ្ទុះឡើងនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែនយ៉ាងណាក្តី។ សង្គ្រាមនេះបានបង្កផលប៉ះពាល់ដោយប្រយោលដល់សេដ្ឋកិច្ចកម្ពុជា តាមរយៈការកើនឡើងថ្លៃទំនិញគ្រប់ប្រភេទ ពិសេសប្រេងឥន្ធនៈ និងវត្ថុធាតុដើមកសិកម្មរួមមាន÷ ជី និងថ្នាំសម្លាប់សត្វល្អិត ជាដើម។ ទន្ទឹមនេះ ការកើនឡើងថ្លៃជារួម បានបង្កផលប៉ះពាល់ដល់សកម្មភាពចាយវាយ និងប្រើប្រាស់ក្នុងស្រុក ក៏ដូចជាជីវភាពរស់នៅរបស់ប្រជាជន។ ទោះជាយ៉ាងនេះក្តី ផលប៉ះពាល់នៃសង្គ្រាមនេះមកលើសេដ្ឋកិច្ចកម្ពុជា គឺមានទំហំតូចដោយហេតុថាទំនាក់ទំនងសេដ្ឋកិច្ចដោយផ្ទាល់រវាងកម្ពុជាជាមួយនឹងប្រទេសជម្លោះទាំងពីរមានកម្រិតទាប។ ផលប៉ះពាល់នេះត្រូវបានប៉ះប៉ូវមកវិញមួយផ្នែកធំ តាមរយៈការសម្រេចបាននូវអាត្រាខ្ពស់នៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបានធ្វើឱ្យកម្ពុជាបង្កើតបាននូវ **ភាពស៊ាំសហគមន៍** ជាមូលដ្ឋានសំខាន់សម្រាប់ការបើកប្រទេសឡើងវិញ និងបានអនុញ្ញាតឱ្យសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកចាប់ផ្តើមវិលត្រឡប់ទៅរកភាពប្រក្រតីវិញ។ បន្ថែមលើនេះ, ការបន្តដាក់ចេញនូវវិធានការអន្តរាគមន៍មុតស្រួចរបស់រាជរដ្ឋាភិបាលក្នុងការជួយរក្សាលំនឹងធុរកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន ជាពិសេសកម្មករ-និយោជិត និងគ្រួសារក្រីក្រ និងជនងាយរងគ្រោះ ដែលទទួលរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ ក៏រំពឹងថានឹងបន្តចូលរួមចំណែកទ្រទ្រង់កំណើនសេដ្ឋកិច្ចជារួម សម្រាប់ឆ្នាំ២០២២។

សម្រាប់ឆ្នាំ២០២៣, សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងសម្រេចបានអត្រាកំណើនក្នុងរង្វង់ ៦,៦% ដោយសារការរំពឹងទុកនៃការបន្តនិន្នាការល្អប្រសើរនៃតម្រូវការសកល និងទំនុកចិត្តវិនិយោគ ស្របពេលដែលវិបត្តិជំងឺកូវីដ-១៩ មានភាពស្រាកស្រាន្ត និងអាចគ្រប់គ្រងបាន។ ទន្ទឹមនេះ, " **ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣**" នឹងបន្តរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញ និងការបង្កើនតម្លៃបន្ថែមទៀតដល់អនុវិស័យជំរុញកំណើនដែលមានស្រាប់ ក៏ដូចជាលើកកម្ពស់អនុវិស័យសក្តានុពលដែលជាចន្លល់កំណើនថ្មី រួមមាន÷ អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ និងអនុវិស័យគមនាគមន៍ ព្រមទាំងការអភិវឌ្ឍវិស័យសហគ្រាសធុនតូច និងមធ្យម។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាលបានគិតគូរបង្កើនកញ្ចប់អន្តរាគមន៍ ជាពិសេសផ្នែកសង្គម និងសេដ្ឋកិច្ច ដើម្បីជួយកាត់បន្ថយផលប៉ះពាល់ពីការកើនឡើងអតិផរណា និងការបង្កើនការវិនិយោគក្នុងស្រុក ដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងបង្កើតការងារជូនប្រជាជនផងដែរ។

ក្នុងឆ្នាំ២០២២ អតិផរណាត្រូវបានប៉ាន់ស្មានថានឹងអាចកើនឡើងក្នុងរង្វង់ ៥,០% ដោយសារការកើនឡើងខ្ពស់នៃថ្លៃប្រេងអន្តរជាតិ និងថ្លៃទំនិញផ្សេងៗទៀត បណ្តាលមកពីសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន។ សម្រាប់ឆ្នាំ ២០២៣, អតិផរណាត្រូវបានរំពឹងថានឹងថមថយមកវិញក្នុងរង្វង់ ២,៥% ដោយសារការរំពឹងទុកនូវការវិលត្រឡប់ទៅរកប្រក្រតីភាពវិញនៃថ្លៃប្រេង និងទំនិញផ្សេងៗទៀត ក៏ដូចជាសកម្មភាពសេដ្ឋកិច្ច។

អត្រាប្តូរប្រាក់រំពឹងថានឹងស្ថិតក្នុងរង្វង់ជាមធ្យមប្រចាំឆ្នាំប្រមាណ ៤ ០៦៥ រៀល ក្នុងមួយដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០២២ និងឆ្នាំ២០២៣ ដោយសារអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជាក្នុងការរក្សាស្ថិរភាពថ្លៃ និងទំនុកចិត្តពីសាធារណជនលើការប្រើប្រាស់ប្រាក់រៀល។

ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែ) ត្រូវបានប៉ាន់ស្មានថានឹងរួមតូចមកវិញក្នុងទំហំប្រមាណ ២៦,៨% នៃ ផសស ក្នុងឆ្នាំ២០២២ ធៀបនឹង ៤៥,៤% នៃ ផសស ឆ្នាំ២០២១ ក្រោមការរំពឹងទុកនូវការត្រឡប់ទៅរកប្រក្រតីភាពនៃសមតុល្យពាណិជ្ជកម្ម ក្នុងខណៈដែលចំណូលពីភ្ញៀវទេសចរអន្តរជាតិ និងប្រាក់បញ្ញើពីក្រៅប្រទេស ក៏ត្រូវបានរំពឹងថានឹងងើបឡើងវិញសន្សឹមៗ ស្របតាមភាពស្រាកស្រាន្តនៃស្ថានភាពនៃវិបត្តិជំងឺកូវីដ-១៩ជាបណ្តើរៗ។ សម្រាប់ឆ្នាំ២០២៣ ឱនភាពគណនីចរន្តរំពឹងថានឹងបន្តរួមតូចក្នុងរង្វង់ ១៤,១% នៃ ផសស ដោយសារការរំពឹងទុកនូវការបន្តកើនឡើងនៃការនាំចេញ និងការបន្តនិន្នាការងើបឡើងនៃចំណូលពីភ្ញៀវទេសចរអន្តរជាតិ។ ជាមួយគ្នានេះ, វិហ្វូវិនិយោគផ្ទាល់ពីបរទេសសម្រាប់ឆ្នាំ២០២២ និងឆ្នាំ២០២៣ ត្រូវបានរំពឹងថានឹងងើបឡើងក្នុងរង្វង់ ១២,០% នៃ ផសស និង ១១,៦% នៃ ផសស រៀងគ្នា ដោយសារការបន្តកើនឡើងនូវទំនុកចិត្តវិនិយោគ ជារួមនឹងបរិយាកាសកាន់តែអំណោយផលរបស់កម្ពុជាក្នុងបរិការណ៍នៃការផ្លាស់ប្តូរកាន់តែលឿននូវខ្សែច្រវាក់ផលិតកម្ម និងផ្គត់ផ្គង់តំបន់ និងសកល ស្របពេលដែលវិបត្តិជំងឺកូវីដ-១៩មានភាពស្រាកស្រាន្ត។ ជាលទ្ធផល, ទុនបម្រុងអន្តរជាតិសរុប ត្រូវបានរំពឹងថានឹងបន្តកើនឡើងដល់ ២១ ២៧១ និង ២២ ១៥៥ លានដុល្លារអាម៉េរិក ដែលធានាការនាំចូលបានប្រមាណ ៧,៧ និង ៧,៦ ខែ ក្នុងឆ្នាំ២០២២ និងឆ្នាំ២០២៣ រៀងគ្នា។

### ២.២. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងវិមជ្ឈការហិរញ្ញវត្ថុ

យោងតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៣ សរណន ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២ ដើម្បីសម្រេចបានគោលដៅក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចខាងលើ រាជរដ្ឋាភិបាល បានកំណត់គោលដៅសូចនាករហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ២០២៣ ដូចខាងក្រោម÷

- ចំណូលក្នុងស្រុកសរុបសម្រាប់ឆ្នាំ ២០២៣ ត្រូវគ្រោងសម្រេចឱ្យបាន ២១,៨៩% នៃ ផសស ក្នុងនោះចំណូលចរន្តក្នុងទំហំ ២១,៦៤% នៃ ផសស និងចំណូលមូលធនក្នុងទំហំ ០,២៥% នៃ ផសស។ ចំណូលចរន្តត្រូវគ្រោងកើនឡើង ១៧,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២ ដែលក្នុងនោះថ្នាក់ជាតិត្រូវសម្រេចឱ្យបានប្រមាណ ១៩,៦៩% នៃ ផសស និងសម្រាប់ថ្នាក់ក្រោមជាតិ ១,៩៥% នៃ ផសស។ ដោយឡែក ការប្រមូលចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវគ្រោងសម្រេចឱ្យបាន ១១,០% នៃ ផសស, ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាត្រូវគ្រោងសម្រេចឱ្យបាន ៨,៤៨% នៃផសស និងចំណូលមិនមែនសារពើពន្ធត្រូវគ្រោងសម្រេចឱ្យបាន ២,១៦% នៃ ផសស។
- ចំណាយសរុបថវិការដ្ឋនៅឆ្នាំ ២០២៣ នឹងកំណត់ក្នុងរង្វង់ ២៩,៤៣% នៃ ផសស ក្នុងនោះចំណាយសរុបថវិកាថ្នាក់ជាតិ ២៧,៤៨% នៃ ផសស និងចំណាយសរុបថវិកាថ្នាក់ក្រោមជាតិ ២,៩៥% នៃ ផសស ដោយរួមបញ្ចូលទាំងការឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិចំនួន ១,០% នៃ ផសស។ ចំណាយចរន្តថវិការដ្ឋ ត្រូវកំណត់ក្នុងកម្រិត ១៧,៦៥% នៃ ផសស ដែលក្នុងនោះ÷

- ចំណាយបន្ទុកបុគ្គលិក មានសមាមាត្រស្មើនឹង ៤៤,៤៥% នៃចំណាយចរន្តថវិការដ្ឋត្រូវជា ៧,៨៥% នៃ ផសស ដោយផ្ដោតអាទិភាពទៅលើការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ ក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅ, បង្កើនផលិតភាពការងារ និងពង្រឹងប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ ដោយឈរលើគោលការណ៍សមធម៌ គុណាធិបតេយ្យ និងចីរភាពថវិកា
- ចំណាយក្រៅបន្ទុកបុគ្គលិក មានសមាមាត្រស្មើនឹង ៥៥,៥៥% នៃចំណាយចរន្តថវិការដ្ឋត្រូវជា ៩,៨១% នៃ ផសស ដោយផ្ដោតអាទិភាពលើ÷ (១)-ការបន្តគាំពារ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដោយយកមនុស្សជាអាទិភាពទី១ ព្រមទាំងរៀបចំមូលដ្ឋានសង្គមកម្ពុជាឱ្យកាន់តែមានភាពធន់រឹងមាំ តាមរយៈការពន្លឿនការកែទម្រង់ក្នុងវិស័យអប់រំ, ការលើកកម្ពស់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការពង្រឹងគុណភាព និងការពង្រីកវិសាលភាពនៃវិស័យសុខាភិបាល និងប្រព័ន្ធគាំពារសង្គម និង (២)-ការសម្រេចឱ្យបាននូវរាល់គោលដៅអាទិភាពនៃរបៀបវារៈគោលរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា នៅឆ្នាំ២០២៣ ដែលជាឆ្នាំចុងក្រោយនៃអាណត្តិ។

➢ ចំណាយមូលធន ត្រូវបានគ្រោងបង្កើនដល់ប្រមាណជា ១១,៧៨% នៃ ផសស ដោយផ្ដោតអាទិភាពលើ (១)-ការជំរុញវិស័យជាចន្ទល់កំណើនសេដ្ឋកិច្ច ស្របតាមការចង្អុលបង្ហាញ នៅក្នុង **ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្ដារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ ២០២១-២០២៣**, (២)- ការបន្តស្ដារ និងកសាងហេដ្ឋារចនាសម្ព័ន្ធ ដែលរួមទាំងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់, ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបៃតង ដើម្បីជំរុញពិពិធកម្មសេដ្ឋកិច្ចលើកកម្ពស់ភាពប្រកួតប្រជែង និងផ្ដល់សម្ទុះបន្ថែមដល់កិច្ចអភិវឌ្ឍន៍សង្គមកម្ពុជាបន្ទាប់ពីវិបត្តិនៃជំងឺកូវីដ-១៩។

សរុបចំណាយថវិកាថ្នាក់ជាតិ ដែលរួមបញ្ចូលទាំងហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងវិភាជទៅតាមវិស័យ ដូចជា÷ វិស័យរដ្ឋបាលទូទៅ ត្រូវបានគ្រោងប្រមាណ ១,៧៥% នៃ ផសស, វិស័យការពារជាតិ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ ត្រូវបានគ្រោងប្រមាណ ៣,៩១% នៃ ផសស, វិស័យសង្គមកិច្ច ត្រូវបានគ្រោងប្រមាណ ៨,២៥% នៃ ផសស, និងវិស័យសេដ្ឋកិច្ច ត្រូវបានគ្រោងប្រមាណ ៧,១១% នៃ ផសស។ ក្រៅពីចំណាយលើវិស័យទាំងបួន នៅមានចំណាយផ្សេងៗ ត្រូវបានគ្រោងក្នុងទំហំ ៦,៤៥% នៃ ផសស ដើម្បីធានាបាននូវលទ្ធភាពអន្តរាគមន៍ភ្លាមៗ ក្នុងការដោះស្រាយនូវបញ្ហាសង្គម-សេដ្ឋកិច្ច និងត្រៀមបម្រុងសម្រាប់ការអនុវត្តគោលនយោបាយនានា, ការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ, ការវិភាជកញ្ចប់ថវិកាសម្រាប់ការរៀបចំព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ និងកិច្ចការបន្ទាន់ចំពោះមុខរបស់រាជរដ្ឋាភិបាល រួមទាំងការបន្តធ្វើអន្តរាគមន៍ឆ្លើយតបទៅនឹងផលប៉ះពាល់នៃជំងឺកូវីដ-១៩។

ដូចនេះ ដោយឈរលើមូលដ្ឋានក្របខ័ណ្ឌចំណូល និងចំណាយខាងលើ, អតិរេកថវិកាចរន្តសម្រាប់ឆ្នាំ២០២៣ នឹងសម្រេចបានប្រមាណ ៣,៩៩% នៃ ផសស និងឱនភាពថវិកាសរុបនឹងមានទំហំ -៧,៥៤% នៃ ផសស។ ក្នុងក្របខ័ណ្ឌនេះ, ថវិកាឆ្នាំ២០២៣ ជាឆ្នាំចុងក្រោយនៃនីតិកាលទី៦ នៃរដ្ឋសភា

មានចរិតជា **ថវិកាវិន្ទាកម្មចំគោលដៅ** ដោយឈរលើគោលការណ៍ប្រសិទ្ធភាពថវិកា សំដៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ និងរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងគាំទ្រដល់ការជំរុញកំណើនសេដ្ឋកិច្ច ស្របតាមទិសដៅជាយុទ្ធសាស្ត្រ ដែលបានដាក់ចេញនៅក្នុង " ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ ២០២១-២០២៣"។

ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ, ការគ្រោងថវិកាឆ្នាំ២០២៣ និងឆ្នាំបន្តបន្ទាប់ ត្រូវរៀបចំឡើងឈរលើមូលដ្ឋានយុទ្ធសាស្ត្រ និងក្របខ័ណ្ឌនៃវិធានការផ្នែកចំណូល និងវិធានការផ្នែកចំណាយ។ វិធានការផ្នែកចំណូលរួមមាន វិធានការផ្នែកចំណូលពន្ធដារ, វិធានការផ្នែកចំណូលគយ និងរដ្ឋាករ និងវិធានការផ្នែកចំណូលមិនមែនសារពើពន្ធ។ រីឯវិធានការផ្នែកចំណាយ, ដើម្បីសម្រេចបាននូវគោលដៅរក្សាស្ថិរភាពសង្គម និងទ្រទ្រង់ដល់ការងើបឡើងនូវកំណើនសេដ្ឋកិច្ច, រាជរដ្ឋាភិបាលចាំបាច់ត្រូវពង្រឹងទាំងប្រសិទ្ធភាពវិភាជន៍ និងទាំងប្រសិទ្ធភាពប្រតិបត្តិការ និងការឆ្លើយតបទៅនឹងទិសដៅគោលនយោបាយ និងកម្មវិធីកែទម្រង់នានាតាមរយៈវិធានការសំខាន់ៗក្នុងឆ្នាំ ២០២៣ រួមមាន÷ បន្តដាក់ចេញនូវកញ្ចប់ថវិកាអន្តរាគមន៍, តម្រង់ធនធានថវិកាលើវិស័យគន្លឹះ, កំណត់លក្ខខណ្ឌជ្រើសរើសក្របខ័ណ្ឌថ្មីសម្រាប់ទាំងផ្នែកមន្ត្រីរាជការ យោធិន នគរបាលជាតិ និងស្ថាប័នឯករាជ្យ, បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ, ជំរុញការអនុវត្តកម្មវិធីកំណែទម្រង់នានា, បន្តពង្រឹងគុណភាព និងពង្រីកវិសាលភាពនៃសេវាសាធារណៈ, បន្តកែលម្អគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃផែនការយុទ្ធសាស្ត្រថវិកា, បន្តពង្រឹងការអនុវត្តថវិកាកម្មវិធីនៅគ្រប់ក្រសួង-ស្ថាប័ន (រួមបញ្ចូលរដ្ឋបាលរាជធានី-ខេត្ត), បន្តអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ, បន្តពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធ FMIS ដល់គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ដោយផ្អែកលើមូលដ្ឋាននៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងដើម្បីសម្រេចបានគោលដៅនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, គម្រោងថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០២៣ ត្រូវបានគ្រោង និងអនុញ្ញាតនូវប្រភពធនធាន និងបន្ទុកចំណាយទាំងអស់ ដោយត្រូវធានាឱ្យបាននូវតុល្យភាពនៃថវិកា។ សម្រាប់ឆ្នាំ ២០២៣, ចំណាយចរន្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ត្រឹម ២,៥៦% នៃផ.ស.ស. កើនឡើង ១១,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២២ ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក ០,៦៥% នៃ ផសស និងចំណាយក្រៅបន្ទុកបុគ្គលិក ១,៩១% នៃ ផសស ដែលត្រូវប្រើប្រាស់ថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ សរុបមានប្រមាណ ១,៥៦% នៃ ផសស និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់រដ្ឋបាលថ្នាក់ក្រោមជាតិស្មើនឹង ១,០០% នៃផ.ស.ស ដែលក្នុងនោះ÷

- ថវិការដ្ឋបាលរាជធានី ខេត្ត មានប្រភពចំណូលនៅមូលដ្ឋានដែលរួមមាន ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ ចំណូលឧបត្ថម្ភពីថ្នាក់ជាតិ និងចំណូលផ្សេងៗទៀតដែលកំណត់ដោយច្បាប់។ ចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្ត នឹងត្រូវបែងចែកជូនរដ្ឋបាលក្រុង ស្រុក ក្នុងអត្រា ៤% នៃចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្តឆ្នាំ២០២២ ជាមួយគ្នានេះ ចំណូល

សារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្ត នឹងត្រូវបែងចែកជូនរដ្ឋបាលឃុំ សង្កាត់ (លើកលែងសង្កាត់ចំណុះរាជធានីភ្នំពេញ) ក្នុងអត្រា ៥.៥% នៃចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្ត ឆ្នាំ២០២២ ដើម្បីបង្កើនធនធានជូនរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន។

- ថវិកាឧបត្ថម្ភមូលនិធិក្រុង ស្រុក ត្រូវបានវិភាជក្នុងកម្រិតអត្រា ១,៥% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០២២។ ការវិភាជមូលនិធិក្រុង ស្រុក ត្រូវបានគណនាតាមរូបមន្តជាក់លាក់ស្របតាមអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨។ នៅឆ្នាំ២០២៣ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្ត ក្នុងអត្រា ៤% នៃចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្តឆ្នាំ២០២២ ជូនរដ្ឋបាលក្រុង ស្រុក សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន។ ជាមួយគ្នានេះផងដែរ សម្រាប់ឆ្នាំ២០២៣ រដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងទទួលបានថវិកាឧបត្ថម្ភពីថ្នាក់ជាតិ សម្រាប់ចំណាយអនុវត្តមុខងារនៃការិយាល័យជំនាញរបស់មន្ទីរជំនាញរាជធានី ខេត្ត ដែលបានធ្វើសមាហរណកម្មចូលទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានចំនួន ២០វិស័យ។
- ថវិកាឧបត្ថម្ភមូលនិធិឃុំ សង្កាត់ ត្រូវបានវិភាជក្នុងកម្រិតអត្រា ៣,៤% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០២២។ ការវិភាជមូលនិធិឃុំ សង្កាត់ត្រូវបានគណនាតាមរូបមន្តជាក់លាក់ស្របតាមអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨។ នៅឆ្នាំ២០២៣, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្ត ក្នុងអត្រា ៥.៥% នៃចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្តឆ្នាំ២០២២ ជូនរដ្ឋបាលឃុំ សង្កាត់ (លើកលែងសង្កាត់ចំណុះរាជធានីភ្នំពេញ) សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន។ ជាមួយគ្នានេះផងដែរ រាជរដ្ឋាភិបាលនឹងធ្វើការផ្ទេរធនធានថវិកាបន្ថែមលើមូលនិធិឃុំ សង្កាត់ (លើកលែងសង្កាត់ចំណុះរាជធានីភ្នំពេញ) សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ស្មើនឹងអត្រា ១% នៃចំណូលចរន្តថវិកាថ្នាក់ជាតិដែលបានអនុម័តឆ្នាំ២០២២។
- ទន្ទឹមនឹងនេះ, រដ្ឋបាលថ្នាក់ក្រោមជាតិនឹងទទួលបាននូវធនធានមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ ដើម្បីប្រើប្រាស់ និងអនុវត្តមុខងារជាក់លាក់មួយចំនួនដែលបានផ្ទេរពីក្រសួង ស្ថាប័ន។ យន្តការនេះបាន និងកំពុងអនុវត្តសម្រាប់ការវិភាជធនធានពីក្រសួង ស្ថាប័ន ទៅរដ្ឋបាលក្រុង ស្រុក តាមរយៈការផ្ទេរមុខងារ ហើយក្រសួង ស្ថាប័នមួយចំនួនទៀតកំពុងបន្តជំរុញការផ្ទេរមុខងារទៅរដ្ឋបាលក្រុង ស្រុកមួយចំនួនថែមទៀត។

## ៣. រចនាសម្ព័ន្ធនៃឯកសារផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តឆ្នាំ២០២៣-២០២៥

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ ដែលបានគូសរំលេចខាងលើ បានកំណត់អំពីគោលដៅរួមនៃការប្រមូលចំណូល និងការអនុវត្តចំណាយ ដោយបានដាក់ចេញនូវវិធានការចាំបាច់ និងជាក់ស្តែងដែលត្រូវអនុវត្តដើម្បីសម្រេចគោលដៅទាំងនេះ និងបានកំណត់អំពីប្រភពធនធាន និងបន្ទុកចំណាយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូច្នេះ រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្អែកលើក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

និងគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ ដើម្បីឈានទៅរៀបចំផែនការយុទ្ធសាស្ត្ររបស់ខ្លួនឱ្យបានត្រឹមត្រូវ និងមានភាពជាក់ស្តែង។ ទន្ទឹមនឹងនេះ ដើម្បីជាមូលដ្ឋានសម្រាប់ឱ្យរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ អាចរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈឯកភាពគ្នាទាំងរចនាសម្ព័ន្ធ និងទាំងខ្លឹមសារ ព្រមទាំងអាចធ្វើការតម្រឹមជាមួយនឹងអាទិភាពតាមវិស័យនៃក្រសួង ស្ថាប័នថ្នាក់ជាតិសម្រាប់ថវិកាមន្ទីរជំនាញរាជធានី ខេត្ត និងធ្វើសមាហរណកម្មផែនការ/កម្មវិធីនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីទម្រង់នៃផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ដូចតទៅ÷

**ផ្នែកទី១ : សេចក្តីផ្តើម**

ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ ត្រូវចាប់ផ្តើមដោយការរៀបរាប់អំពីតួនាទី និងបេសកកម្មចម្បងៗរបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ អំពីស្ថានភាពជាក់ស្តែងនៃការអនុវត្តផែនការថវិកាកន្លងទៅ ជាពិសេសលទ្ធផលសម្រេចបានក្នុងឆ្នាំមុន (ឆ្នាំ n-1) ធៀបនឹងសូចនាករដែលបានកំណត់ដោយលើកឡើងនូវវិស័យចម្បងទាំង៤ ដែលរួមមាន÷ សេដ្ឋកិច្ច, សង្គមកិច្ច, សន្តិសុខ និងសុវត្ថិភាពសាធារណៈ, និងរដ្ឋបាលទូទៅ។ ផ្តល់នូវសេចក្តីពណ៌នាបែបវិភាគសង្ខេបអំពីបញ្ហាប្រឈមនៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំមុន (ឆ្នាំ n-1) និងចំណុចពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តថវិកាជាក់ស្តែងប្រចាំឆ្នាំ ដូចជាកង្វះមន្ត្រី ឬបុគ្គលិកដែលមានគុណវុឌ្ឍិ, បញ្ហាការអនុវត្តលទ្ធកម្ម, ការធ្វើប្រតិភូកម្មសិទ្ធិអំណាចមិនទាន់បានគ្រប់គ្រាន់ និងផ្សេងៗ ព្រមទាំងលើកឡើងអំពីវិធានការចាំបាច់មួយចំនួនដែលគ្រោងនឹងអនុវត្តដើម្បីកាត់បន្ថយបញ្ហាប្រឈម។ បន្ទាប់មកត្រូវមានការរៀបរាប់អំពីវិធានការគោលនយោបាយសំខាន់ៗ សម្រាប់រួមចំណែកដល់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ *សូមរៀបចំខ្លឹមសារនេះនៅផ្នែកទី១នៃឧបសម្ព័ន្ធទី១ ទៅតាមគំរូតារាងដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។*

**ផ្នែកទី២ : គោលបំណងគោលនយោបាយ**

គោលបំណងគោលនយោបាយរបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ត្រូវរៀបចំឡើងសម្រាប់ចក្ខុវិស័យរយៈពេលមធ្យម និងវែង (៣-៥ឆ្នាំ) ដោយផ្អែកលើគោលនយោបាយតាមវិស័យដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ត្រូវពិនិត្យ និងវាយតម្លៃលើផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤ ដើម្បីកំណត់ពីសុពលភាពនៃគោលបំណងគោលនយោបាយនោះ ដែលនាំឱ្យមានការកែសម្រួលគោលបំណងគោលនយោបាយសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥។ ទន្ទឹមនឹងនេះ, ការផ្លាស់ប្តូរមុខងារ និងភារកិច្ចរបស់រដ្ឋបាលនីមួយៗក៏ជាកត្តាសំខាន់មួយ ដែលធ្វើឱ្យគោលបំណងគោលនយោបាយមានការផ្លាស់ប្តូរដែរ។ ទោះបីជាយ៉ាងនេះក្តី, គោលបំណងគោលនយោបាយដែលបង្កើតឡើងត្រូវតែមានគោលដៅបម្រើឱ្យវិស័យអាទិភាពទាំងបួន (៤) គឺ÷ វិស័យសេដ្ឋកិច្ច, សង្គមកិច្ច, សន្តិសុខ និងសុវត្ថិភាពសាធារណៈ, និងរដ្ឋបាលទូទៅ។ *សូមរៀបចំខ្លឹមសារនេះនៅផ្នែកទី២នៃឧបសម្ព័ន្ធទី១ នេះទៅតាមគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។*

**ផ្នែកទី៣: អំពីរចនាសម្ព័ន្ធកម្មវិធី**

នៅក្នុងផ្នែកនេះ គឺជាការរៀបរាប់ និងពន្យល់អំពីរចនាសម្ព័ន្ធកម្មវិធី ដែលត្រូវបានរៀបចំឡើង ដើម្បីអនុវត្តគោលបំណងគោលនយោបាយ។ ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ត្រូវបានកំណត់ឱ្យមានកម្មវិធីយ៉ាងច្រើនបំផុតត្រឹម ០៤ កម្មវិធី ដើម្បីផ្តល់ភាពងាយស្រួលក្នុងការតម្រឹមផែនការ/កម្មវិធីនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងអាទិភាពតាមវិស័យនៃក្រសួង ស្ថាប័នថ្នាក់ជាតិសម្រាប់ថវិកាមន្ទីរជំនាញរាជធានី ខេត្ត។ ដោយឡែក, សម្រាប់ចំនួនអនុកម្មវិធី និងចង្កោមសកម្មភាពពុំមានកំណត់ចំនួនឡើយ។ ការរៀបចំរចនាសម្ព័ន្ធកម្មវិធី គឺត្រូវតែឆ្លុះបញ្ចាំងអំពីការផ្សារភ្ជាប់ទំនាក់ទំនង ជាមួយនឹងគោលបំណងគោលនយោបាយ និងត្រូវមានអ្នកទទួលខុសត្រូវច្បាស់លាស់ដើម្បីធានាការផ្សារភ្ជាប់រវាងផែនការ/កម្មវិធីទៅនឹងថវិកា។ *សូមរៀបចំខ្លឹមសារនេះនៅផ្នែកទី៣នៃឧបសម្ព័ន្ធទី១ទៅតាមគំរូតារាងទី១.១ ដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។*

**ផ្នែកទី៤: សូចនាករសមិទ្ធកម្មគន្លឹះ និងគោលដៅនៃសូចនាករសមិទ្ធកម្មគន្លឹះ**

កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព ត្រូវតែមានការតាមដាន និងវាស់លទ្ធផលសម្រេចបានពីការអនុវត្តជាក់ស្តែង តាមរយៈការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ និងគោលដៅសូចនាករសមិទ្ធកម្មគន្លឹះ។ នៅក្នុងការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ត្រូវកំណត់ទាំងសូចនាករលទ្ធផលក្នុងឆ្នាំ និងទាំងសូចនាករលទ្ធផលចុងក្រោយ។ សូចនាករលទ្ធផលក្នុងឆ្នាំ គឺជារង្វាស់ដែលអាចកំណត់គោលដៅសមិទ្ធកម្មនៃការអនុវត្តអនុកម្មវិធី និងចង្កោមសកម្មភាពនៅក្នុងរយៈពេលជាក់លាក់មួយ (មិនលើសពីមួយឆ្នាំ)។ រីឯសូចនាករលទ្ធផលចុងក្រោយ គឺជារង្វាស់ដែលអាចកំណត់គោលដៅសមិទ្ធកម្មចុងក្រោយ ដែលជាលទ្ធផលបង្កើតឡើងដោយលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធីក្នុងរយៈពេលមធ្យម និងវែង (លើសពីមួយឆ្នាំ)។ សូចនាករអាចមានសូចនាករបន្ថែមថ្មី និងសូចនាករចាស់ដែលត្រូវកែសម្រួល។ ការកំណត់សូចនាករនីមួយៗត្រូវមានការពន្យល់ពីមូលហេតុ។ ចំពោះសូចនាករចាស់ ត្រូវបញ្ជាក់អំពីស្ថានភាពនៃការអនុវត្តឆ្នាំ២០២១, ការព្យាករស្ថានភាពនៃការអនុវត្តក្នុងឆ្នាំ២០២២ និងធ្វើបច្ចុប្បន្នភាពតាមជាក់ស្តែង។ កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពនីមួយៗ អាចមានសូចនាករច្រើន ប៉ុន្តែរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ត្រូវជ្រើសរើសសូចនាករក្នុងកម្រិតមួយសមស្រប និងគ្រប់គ្រាន់ដែលធានាសម្រេចឱ្យបាននូវការអនុវត្ត។ *សូមរៀបចំខ្លឹមសារនេះនៅផ្នែកទី៤នៃឧបសម្ព័ន្ធទី១ទៅតាមគំរូតារាងទី១.២ ដែលបានភ្ជាប់មកជាមួយសារាចរណែនាំនេះ។*

**ផ្នែកទី៥: ការកំណត់ធនធានថវិកា**

ការគ្រោងចំណូលថវិការដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ គឺជាការគ្រោងចំណូលសម្រាប់រយៈពេល៣ឆ្នាំ (២០២៣-២០២៥) ដោយផ្អែកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈខាងលើ ព្រមទាំងលទ្ធផល និងបទពិសោធន៍ក្នុងការអនុវត្តនៃបណ្តាឆ្នាំកន្លងមក រួមទាំងគោលនយោបាយ និងវិធានការថ្មីដែលគ្រោងនឹងដាក់ឱ្យអនុវត្ត។ ការគ្រោងចំណូលនេះ ត្រូវគិតបញ្ចូលប្រភពចំណូលដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់, ចំណូលដែលបានពីថវិកាជាតិ និងចំណូលដែលបានមកពីថវិកាហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អនុវត្តគម្រោងនៅក្នុងរដ្ឋបាលរបស់ខ្លួន។ *សូមរៀបចំខ្លឹមសារនេះនៅផ្នែកទី៥នៃឧបសម្ព័ន្ធទី១ ទៅតាមគំរូក្នុងតារាង១.៣ ដែលភ្ជាប់មកជាមួយនឹង*

*សារាចរណែនាំនេះ។* នៅក្នុងផ្នែកនេះ, រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ដែលមានប្រភពចំណូល គឺត្រូវរៀបចំយុទ្ធសាស្ត្រ រួមមានទាំងគោលនយោបាយ និងវិធានការសម្រាប់ពង្រឹងការគ្រប់គ្រង និងប្រមូលចំណូល។ នៅក្នុងការគ្រោងចំណូលរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ត្រូវផ្អែកជាសំខាន់លើ÷

- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម
- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ក្រោមជាតិ
- ការវាយតម្លៃការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត។

ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល៣ឆ្នាំ (២០២៣-២០២៥) ទៅតាមយុទ្ធសាស្ត្រអាទិភាពនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធានថវិកា។ ***សូមរៀបចំខ្លឹមសារនេះនៅផ្នែកទី៥នៃឧបសម្ព័ន្ធទី១ទៅតាមគំរូតារាងទី១.៤ ដែលភ្ជាប់មកជាមួយនឹងសារាចរណែនាំនេះ។*** ការកំណត់ពីតម្រូវការធនធាន ត្រូវផ្តោតជាសំខាន់លើកត្តាមួយចំនួនដូចខាងក្រោម÷

- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ជាពិសេសកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ និងទិសដៅសំខាន់ៗក្នុងការកំណត់អាទិភាពនៃចំណាយ
- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ការវាយតម្លៃការអនុវត្តចំណាយក្នុងរយៈពេលកន្លងមក និងការប៉ាន់ស្មានការអនុវត្តចំណាយក្នុងឆ្នាំកំពុងអនុវត្តរបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ
- ការកំណត់តម្រូវការធនធានទៅតាមឆ្នាំនីមួយៗ ត្រូវមានភាពជាក់ស្តែង និងសុក្រឹតដើម្បីឆ្លើយតបទៅតាមតម្រូវការរបស់កម្មវិធីនីមួយៗ។

**ផ្នែកទី៦: សេចក្តីសន្និដ្ឋាន**

ផ្នែកចុងក្រោយ គឺជាការសន្និដ្ឋានទៅលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ និងការលើកទិសដៅកម្មវិធីសកម្មភាព និងវិធានការដើម្បីសម្រេចបានតាមគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥។ ***សូមរៀបចំខ្លឹមសារនេះនៅផ្នែកទី៦ នៃឧបសម្ព័ន្ធទី១ ដូចបានភ្ជាប់ជាមួយសារាចរណែនាំនេះ។***

**៤. សេចក្តីសន្និដ្ឋាន**

ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត និងខណ្ឌ ដែលជាទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ គឺជាកត្តាគន្លឹះសម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំថវិកា និងការបែងចែកធនធានថវិកា។ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត និងខណ្ឌ ឆ្នាំ២០២៣-២០២៥ ឱ្យបានសមស្រប រដ្ឋបាលរាជធានី ខេត្ត និងខណ្ឌ នីមួយៗត្រូវពិនិត្យឡើងវិញ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាក្នុងឆ្នាំកន្លងទៅដោយឈរលើមូលដ្ឋានផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ២០២៣។ ***សូមមើលឧបសម្ព័ន្ធទី២ ដែលភ្ជាប់មកជាមួយសារាចរណែនាំនេះ។***

ក្រោយពីទទួលបានសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងអភិបាលនៃគណៈអភិបាលខណ្ឌ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន ដោយអនុវត្តទៅតាមដំណើរការរៀបចំផែនការយុទ្ធសាស្ត្រថវិកា **តាមគំរូតារាងដូចបានភ្ជាប់មកជាមួយសារាចរណែនាំនេះ។** បន្ទាប់ពីបញ្ចប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត និងខណ្ឌរួចគឺត្រូវដាក់ជូនប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសដែលជាអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬអភិបាលនៃគណៈអភិបាលខណ្ឌ ដើម្បីពិនិត្យ និងសម្រេច រួចផ្ញើជូនទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីធ្វើការបូកសរុប រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ) យ៉ាងយូរបំផុតត្រឹម **ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ២០២២** ដោយភ្ជាប់មកជាមួយនូវផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ព្រមទាំងផែនការយុទ្ធសាស្ត្រថវិការបស់មន្ទីរជំនាញ ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យ និងអាចអញ្ជើញតំណាងរាជធានី ខេត្ត និងខណ្ឌ មកពិគ្រោះ និងសាកសួរព័ត៌មានបន្ថែមក្នុងករណីចាំបាច់។ ក្នុងករណីរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌមានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ)។

ថ្ងៃចន្ទ ១៤រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល:</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- មន្ទីរជំនាញរាជធានី ខេត្ត
- រតនាគាររាជធានី ខេត្ត
- រដ្ឋបាលរាជធានី ខេត្ត
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រដ្ឋបាលឃុំ សង្កាត់
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ